ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ១.៧៦........ស៊ីសរ.កសក.ផ.ផក

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារគ្រប់គ្រងដីរដ្ឋ

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញលិខិតលេខ ១០៩៥ ជនស/កគដ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ១:** ត្រូវបានតែងតាំងសមាសភាពក្រុមការងារស្តីពីការគ្រប់គ្រងដីរដ្ឋដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោក **ហុង ណារិត** | អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- លោក **ជី សុចិន្តា** | អនុប្រធានការិយាល័យផែនការ នៃ នាយកដ្ឋានផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៣- លោក **ស៊ុំ សាឡុន** | នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | សមាជិក |
| ៤-លោក **សេង សារ៉ុន** | ប្រធានការិយាល័យគណនេយ្យ នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក **ចាប ចាន់ដារ៉ា** | អនុប្រធានការិយាល័យផែនការ គណនេយ្យ នៃនាយកដ្ឋានជលផល | សមាជិក |

| | | |
|---|---|---|
| ៦-លោក **ម៉ៅ សុវឌ្ឍន៍** | អនុប្រធានការិយាល័យទទួលពាក្យបណ្តឹងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៧-លោក **ហូ ពុទ្ធា** | អនុប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម | សមាជិក |
| ៨-លោក **ទូច ម៉ុនធឿន** | អនុប្រធានការិយាល័យ អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម នៃនាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ៩-លោក **ស៊ាន កុសល** | អនុប្រធានការិយាល័យផែនការ-គណនេយ្យ នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល | សមាជិក |
| ១០-លោក **ឡឿន សុខុម** | មន្ត្រីរដ្ឋបាលព្រៃឈើ | សមាជិក |
| ១១-លោក **តាន់ សុវណ្ណារត្ន័** | មន្ត្រីនាយកដ្ឋានបច្ចេកទេសនៃអគ្គនាយកដ្ឋានចំការកៅស៊ូ | សមាជិក |
| ១២-លោក **សៀ រ៉ា** | មន្ត្រីការិយាល័យនីតិកម្ម និងផ្សព្វផ្សាយច្បាប់កសិកម្ម នៃនាយកដ្ឋាន នីតិកម្មកសិកម្ម | សមាជិក |
| ១៣- លោក **ហ៊ិន សារិត** | មន្ត្រីវិទ្យាស្ថាន ស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |

**ប្រការ២:** ក្រុមការងារនេះមានភារកិច្ចរៀបចំចងក្រងប្រមូលផ្តុំទិន្នន័យស្ថិតិស្តីពីការប្រើប្រាស់និងគ្រប់គ្រងដីរដ្ឋធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងចំណាត់ថ្នាក់ដី និងសម្របសម្រួលការផ្តល់ពត៌មាន។

**ប្រការ៣:** សមាជិកក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៤:** អគ្គនាយកនៃក្រសួង អគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិង អស់លោកដូចមានរាយនាម ក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេច នេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ចាន់ សារុន

***កន្លែងទទួល:***
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

"ដើម្បីជូនជ្រាប"

- គ្រប់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ខេត្ត-ក្រុង

"ដើម្បីរួមសហការ"

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ